នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ ) |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jun-2018, 11:26
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: សាធារណៈ/Public

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ**
**ទៅនឹងសំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញរបស់ អ៊ឹម ចែម**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោក Nicholas KOUMJIAN

**ចម្លងជូន:**
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម BAIK Kang Jin
ចៅក្រម ហួត វុទ្ធី

**សហមេធាវី អ៊ឹម ចែម**
ប៊ិត ស៊ាងលីម
Wayne JORDASH

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្នុង**
**សំណុំរឿង០០៤/០១ ទាំងអស់**

# I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("សហព្រះរាជអាជ្ញា") គាំទ្រសំណើរបស់ អ៊ឹម ចែម ដែលស្នើសុំឱ្យមានតម្លាភាពធំជាមុននៅក្នុងកិច្ចដំណើរការនីតិវិធី[1]។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាជំទាស់ទៅនឹងការធ្វើចំណាត់ថ្នាក់ឡើងវិញមានកម្រិតដែលបានជ្រើសរើសដាក់មួយចំនួន[2]។ សនិទានភាពនៃការធ្វើចំណាត់ថ្នាក់ឡើងវិញដែល អ៊ឹម ចែម បានពឹងផ្អែក មិនមែនអនុវត្តចំពោះតែចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាប៉ុណ្ណោះទេ[3] ប៉ុន្តែថែមទាំងការដាក់ឯកសាររបស់ភាគីទាំងអស់ និងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ("សចស") និងរបស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿងនេះផងដែរ។

2. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញានៅតែប្រកាន់តាមសំណើរបស់ខ្លួនថា សវនាការលើបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ និងការដាក់ឯកសារពាក់ព័ន្ធ ត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈ និងសុំឱ្យដីកាដំណោះស្រាយ (សម្អាងហេតុ) ត្រូវចេញដោយមានសម្អាងហេតុ និងលទ្ធផលរកឃើញរបស់ សចស ឱ្យបានពេញលេញ រួមទាំង ភស្តុតាងគាំទ្ររបស់វាដែលមាននៅក្នុងនោះផង[4]។ សហព្រះរាជអាជ្ញានឹងដាក់សំណើមួយដោយសុំឱ្យដាក់ដីកាសន្និដ្ឋានស្ថាពរ និងសេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ត្រូវធ្វើចំណាត់ថ្នាក់ឡើងវិញថា សាធារណៈ ក្នុងពេលវេលាមួយសមស្រប។

3. ខណៈដែលសហព្រះរាជអាជ្ញាគាំទ្រចំពោះសំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញរបស់ អ៊ឹម ចែម តែវិបុលកម្មនៃការកោសលុបដែលបានស្នើ គឺធំពេកដែលជាការមិនចាំបាច់ និងមិនមានអានុភាពក្នុង

---

[1] **D304/6/1** សំណើអ្នកស្រី អ៊ឹម ចែម ស្នើសុំធ្វើចំណាត់ថ្នាក់ប្រភេទឯកសារឡើងវិញ នៃចម្លើយតបរបស់ខ្លួនទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ, ១២ មីនា ២០១៨, កថាខណ្ឌ ១ ("សំណើរបស់ អ៊ឹម ចែម")។

[2] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១, ១៩-២១។

[3] **D304/6** ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងខ្លួន តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង, ២៨ វិច្ឆិកា ២០១៦ ("ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ")។

[4] *សូមអាន* **D309/2/1/2** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុបដីកាដំណោះស្រាយ(សម្អាងហេតុ) ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ(សម្អាងហេតុ), ៩ សីហា ២០១៧ ("បណ្តឹងឧទ្ធរណ៍របស់ សពអ ប្រឆាំងនឹងការកោសលុបក្នុងដីកាដំណោះស្រាយ")។

ការផ្តល់ឲ្យសាធារណជននូវព័ត៌មានគ្រប់គ្រាន់ ដើម្បីឲ្យបានជ្រាបត្រឹមត្រូវអំពីកិច្ចដំណើរការនីតិវិធី។

## II. **អ៊ឹម ចែម ស្នើសុំតម្លាភាពសម្រិតសម្រាំង**

4. សហព្រះរាជអាជ្ញាយល់ស្របជាមួយ អ៊ឹម ចែម ថា តម្លាភាពនៃកិច្ចដំណើរការនីតិវិធី "គឺជាបញ្ហាមួយដែលមាន និងកំពុងតែបន្តមាន ផលប្រយោជន៍សាធារណៈសំខាន់ និងការបារម្ភ"[5]។ លើសពីនេះ សហព្រះរាជអាជ្ញាគាំទ្រចំពោះការអះអាងរបស់ អ៊ឹម ចែម អំពីការធ្វើចំណាត់ថ្នាក់ឡើងវិញនៃឯកសារជាសាធារណៈ ដែលនឹងជួយក្នុងការ "ធានាចំពោះរដ្ឋបាលយុត្តិធម៌ឲ្យមានតម្លាភាព និងសុចរិតភាពនៃមរតករបស់ អ.វ.ត.ក"[6]។ ប៉ុន្តែសំណើរបស់ អ៊ឹម ចែម ដែលគាត់ចង់បាន គឺមានតម្លាភាពតែម្ខាង - ដោយអះអាងថា ការធ្វើចំណាត់ថ្នាក់ឡើងវិញគឺជាការចាំបាច់ "ដើម្បីអនុញ្ញាតឲ្យការបរិយាយរបស់ក្រុមមេធាវីត្រូវបានផ្សព្វផ្សាយជាសាធារណៈ"[7]។ តម្លាភាពនៃកិច្ចដំណើរការនីតិវិធី ត្រូវបញ្ចូលសេចក្តីសន្និដ្ឋានរបស់ភាគីទាំងអស់ ព្រមទាំងសនិទានភាព និងសម្អាងហេតុពេញលេញនៃសេចក្តីសម្រេចនានា និងផ្នែកសម្រេចសេចក្តីរបស់ សចស និងរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿងនេះ។

5. ជាឧទាហរណ៍ អ៊ឹម ចែម មិនចង់ឲ្យការសន្និដ្ឋានចុងក្រោយរបស់ សចស ក្លាយជាឯកសារជាសាធារណៈទេ ទោះបីសេចក្តីសន្និដ្ឋាននោះលើកលែងការចោទប្រកាន់ក៏ដោយ ព្រោះថា ការសន្និដ្ឋាននោះ និយាយថា "អ្នកស្រី អ៊ឹម ចែម 'អាចមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ' ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរនានា"[8]។ ផ្ទុយទៅវិញ អ៊ឹម ចែម ចង់ឲ្យការរិះគន់របស់ខ្លួនអំពីដំណើរការ និងការអះអាងរបស់គាត់ចំពោះ "អង្គហេតុមិនពាក់ព័ន្ធ" និង "កំហុសឆ្គងជាច្រើននៅក្នុងការធ្វើអភិក្រមចំពោះ

---

[5] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ២១។

[6] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១។

[7] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១៧។ *សូមអានផងដែរ*, កថាខណ្ឌ១, ១៩-២១។

[8] **D309/2/1/3** ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុបដីកាដំណោះស្រាយ (សម្អាងហេតុ) ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញនៃដីកាដំណោះស្រាយ (សម្អាងហេតុ), ៤ កញ្ញា ២០១៧, កថាខណ្ឌ៥៣, ("ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ សពអប្រឆាំងនឹងការកោសលុបក្នុងដីកាដំណោះស្រាយ") *លើកយោង* ឯកសារ **D308/3** ដីកាដំណោះស្រាយ (សម្អាងហេតុ), ១០ កក្កដា ២០១៧, កថាខណ្ឌ ៣០៧។

ភ័ស្តុតាង” ក្លាយជាសាធារណៈ[9]។ ដូចដែល អ៊ឹម ចែម ធ្លាប់បានទាមទារថា “អំណះអំណាង *ទាំងអស់* ទាក់ទងនឹងការទទួលខុសត្រូវរបស់ អ៊ឹម ចែម នៅក្នុងបទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងនឹងសំណុំរឿងនេះ គឺជាបញ្ហាដែលសហចៅក្រមស៊ើបអង្កេតមិនមានសមត្ថកិច្ច ដោះស្រាយ ដូច្នេះហើយបានជាត្រូវបានកោសលុបនោះ[10] គឺគាត់ហាក់ដូចជាកំពុងតែជួយការពារដល់ទម្រង់នៃតម្លាភាពមួយដែលមានលក្ខណៈវៀចវេរ និងសម្រាប់តែម្ខាង នៅក្រោមរបៀបនៃ “ការជូនដំណឹង” ដល់សាធារណជនដោយតម្លាភាព។

6. អ៊ឹម ចែម ទាមទារថា គាត់នឹងស្វែងរក “នៅក្នុងរយៈពេលខ្លីខាងមុខ នូវការធ្វើចំណាត់ថ្នាក់ឡើងវិញនៃ” ឯកសារដែលបានដាក់ ដូចជា “សេចក្តីជូនដំណឹងអំពីចេតនានៃការលើកលែងការចោទប្រកាន់របស់ សចស[11] ជាដើម។ អ៊ឹម ចែម និយាយថា មូលដ្ឋានសម្រាប់ការធ្វើចំណាត់ថ្នាក់ឡើងវិញដូច្នេះ គឺ “ដូចគ្នា” នឹងមូលហេតុដែលគាំទ្រដល់សំណើសុំបច្ចុប្បន្នរបស់ អ៊ឹម ចែម[12]។ ទោះបីអ៊ឹម ចែម មិនបានលម្អិតពីឯកសារដែលគាត់ចង់ឱ្យដាក់ចំណាត់ថ្នាក់ឡើងវិញក៏ដោយ ក៏គាត់ហាក់ដូចជាចង់ឱ្យកំណត់ត្រឹមតែការធ្វើចំណាត់ថ្នាក់ឡើងវិញនៃឯកសារដែលគាត់បានស្នើឡើង ដែល “បង្ហាញពីអំណះអំណាងរបស់មេធាវីការពារក្តីជាសាធារណៈតែប៉ុណ្ណោះ”[13]។ ប៉ុន្តែ ចំពោះសនិទានភាពដែល អ៊ឹម ចែម ពឹងផ្អែកដើម្បីគាំទ្រដល់ការធ្វើចំណាត់ថ្នាក់ឡើងវិញនៃចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពរ គឺអនុវត្តដោយស្មើភាពគ្នាចំពោះការដាក់ឯកសារ រួមទាំងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ប្រតិចារិកនៃសវនាការលើបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះ និងដីកាដំណោះស្រាយ(សម្អាងហេតុ)ច្បាប់កោសលុបជាសាធារណៈផង។

## III. មូលដ្ឋានសម្រាប់សំណើរបស់ អ៊ឹម ចែម អនុវត្តបានចំពោះគ្រប់ឯកសារទាំងអស់

7. ដោយបានជំទាស់យ៉ាងខ្ជាប់ខ្ជួនចំពោះតម្លាភាពធំទូលាយ ទាក់ទងនឹងដីកាដំណោះស្រាយ(សម្អាងហេតុ)ច្បាប់កោសលុបជាសាធារណៈ និងសវនាការលើបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំ

[9] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ២០។

[10] **D309/2/1/3** ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ សពអ ប្រឆាំងនឹងការកោសលុបក្នុងដីកាដំណោះស្រាយ, កថាខណ្ឌ ៦៣ (សង្កត់ន័យដើម)។

[11] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១៧។

[12] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១៧។

[13] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១៩។

ជម្រុះ[14] សនិទានភាពរបស់ អ៊ឹម ចែម ចំពោះសំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញទៅលើចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពរ - ដែលថា ការសម្ងាត់នៃកិច្ចស៊ើបសួរ ត្រូវតែថ្លឹងថ្លែងឲ្យបានហ្មត់ចត់ធៀបនឹងផលប្រយោជន៍នៃយុត្តិធម៌ និងតម្រូវការចាំបាច់ក្នុងការរក្សាការជូនដំណឹងដល់សាធារណជន[15] - អនុវត្តដោយស្មើភាពគ្នាចំពោះគ្រប់សេចក្តីសន្និដ្ឋានទាំងអស់នៃរឿងក្តីនេះ។

8. **<u>ភាពសម្ងាត់នៃកិច្ចស៊ើបសួរ:</u>** អ៊ឹម ចែម អះអាងនៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៧ គឺនៅពេលជំទាស់ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងកម្រិតនៃការកោសលុបដែលបានប្រើប្រាស់ដោយ សចស នៅក្នុងដីកាដំណោះស្រាយ(សម្អាងហេតុ)ច្បាប់កោសលុបជាសាធារណៈថាៈ "ជាករណីយុត្តិសាស្ត្រ ដែលដំណាក់កាលនៃកិច្ចស៊ើបសួរបានបញ្ចប់ជាផ្លូវការ តែពេលណាដែលអង្គបុរេជំនុំជម្រះបានសម្រេចលើបណ្តឹងឧទ្ធរណ៍ណាមួយ ដែលជំទាស់ដីកាដំណោះស្រាយ[16] តែប៉ុណ្ណោះ!" និងបានថ្លែងថាមាន "តម្រូវការចាំបាច់ក្នុងការរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរ"[17]។ អ៊ឹម ចែម ពេលនេះតវ៉ាថា "អនុលោមតាមដំណាក់កាលនៃការបិទកិច្ចស៊ើបសួរជាផ្លូវការ [ថ្ងៃទី១៨ ធ្នូ ២០១៥] គេគ្មានមូលហេតុនៅសេសសល់សម្រាប់ការរក្សាចំណាត់ថ្នាក់ជាការសម្ងាត់ សម្រាប់ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ"[18] នោះទៀតទេ។

9. ដូចសហព្រះរាជអាជ្ញាបានសង្កត់ធ្ងន់រួចហើយថា វិធាន ៥៦ នៃវិធានផ្ទៃក្នុង ផ្តល់ការកម្រិតដែលមានកំណត់ និងសមហេតុផល អំពីគោលជំហរជំទាស់ដែលថា កិច្ចដំណើរការនីតិវិធីត្រូវតែមានតម្លាភាព *ក្នុងអំឡុងនៃកិច្ចស៊ើបសួរ*[19]។ នៅពេលកិច្ចស៊ើបសួរត្រូវបានបិទ - ដែល អ៊ឹម ចែម ពេលនេះ បានទទួលយក - ភាពសម្ងាត់ដែលតម្រូវដោយវិធាន ៥៦ មិនអនុវត្តទៀតទេ ហើយ

---

[14] *សូមអាន,* **D309/2/1/3** ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ សពអ ប្រឆាំងនឹងការកោសលុបក្នុងដីកាដំណោះស្រាយ **D308/3/1/16** ចម្លើយតបទៅនឹងការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីសវនាការអង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (សម្អាងហេតុ) (D308/3/1/15), ៦ វិច្ឆិកា ២០១៧។ **D308/3/1/19/2**.1 ប្រតិចារិក សវនាការបណ្តឹងឧទ្ធរណ៍, ១២ ធ្នូ ២០១៧, EN 01549680-81។

[15] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១៨។

[16] **D309/2/1/3** ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ សពអ ប្រឆាំងនឹងការកោសលុបក្នុងដីកាដំណោះស្រាយ, កថាខណ្ឌ ៣៩។

[17] **D309/2/1/3** ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ សពអ ប្រឆាំងនឹងការកោសលុបក្នុងដីកាដំណោះស្រាយ, កថាខណ្ឌ ២១។

[18] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១៦។

[19] *សូមអាន,* **D309/2/1/2** បណ្តឹងឧទ្ធរណ៍របស់ សពអ ប្រឆាំងនឹងការកោសលុបក្នុងដីកាដំណោះស្រាយ។

កិច្ចដំណើរការនីតិវិធី ត្រូវត្រឡប់ថយក្រោយទៅរក *ស្ថានភាពដូចដើម* ចំពោះសិទ្ធិអតិបរមារបស់សាធារណជនក្នុងការទទួលបានការជូនដំណឹង។ ដូច្នេះ ឯកសាររបស់ភាគីទាំងអស់ និងសេចក្ដីសម្រេចរបស់ សចស និងអង្គបុរេជំនុំជម្រះ ត្រូវតែជាសាធារណៈ ក្រោមការកោសលុបដោយសារភាពចាំបាច់នៃការថែរក្សាសុវត្ថិភាពរបស់សាក្សី និងជនរងគ្រោះ។

10. <u>**ផលប្រយោជន៍នៃយុត្តិធម៌:**</u> អ៊ឹម ចែម ទាមទារថា ការធ្វើចំណាត់ឡើងវិញចំពោះចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពរ នឹង“ធានាបានចំពោះរដ្ឋបាលយុត្តិធម៌ដោយតម្លាភាព និងសុចរិតភាពចំពោះមរតករបស់ អ.វ.ត.ក”[20]។ អ៊ឹម ចែម អះអាងថា បច្ចុប្បន្នមានកំណត់ហេតុសាធារណៈដែលមិនត្រឹមត្រូវ និងធ្វើឲ្យមានការយល់ច្រឡំចំពោះសំណុំរឿងនេះ ហើយបានលើកយោង *ជាអាទិ៍* សេចក្ដីសង្ខេបរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៥៤ នៃវិធានផ្ទៃក្នុង ដែលអាចរកបានជាសាធារណៈ[21]។ ទោះបីជាមានការភាន់ច្រឡំមួយអំពីការកំណត់ចរិកលក្ខណៈក្នុងសេចក្ដីសង្ខេបរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៥៤ ក៏ដោយ អ៊ឹម ចែម នៅតែទាមទារថា កំណត់ហេតុជាសាធារណៈនៃរឿងក្ដីនេះ គឺមានកំហុស មិនអាចធ្វើឧបាស្រ័យត្រឹមការធ្វើចំណាត់ថ្នាក់ឡើងវិញដោយសម្រិតសម្រាំងនោះឡើយ - ប៉ុន្តែគេអាចធ្វើបាន ទាល់តែមានការធ្វើចំណាត់ថ្នាក់ឡើងវិញជាសាធារណៈ នូវសេចក្ដីសន្និដ្ឋានរបស់គ្រប់ភាគី និងសេចក្ដីសម្រេចទាំងអស់របស់ សចស និងអង្គបុរេជំនុំជម្រះ។

11. ជាការបន្ថែម អ៊ឹម ចែម គាំទ្រចំពោះការទាមទាររបស់គាត់អំពីកំណត់ហេតុជាសាធារណៈដែលមិនត្រឹមត្រូវ និងដែលនាំឲ្យយល់ច្រឡំ តាមរយៈការលើកយោងអត្ថបទកាសែតមួយស្ដីពីការលំបាកនៅពេលបានដឹងពីអ្វីដែល សចស បានសម្រេចក្នុងដីកាដំណោះស្រាយ(សម្អាងហេតុ) ដោយសារតែភាពលើសលុបនៃការកោសលុបឯកសារនេះ[22]។ ទាក់ទងនឹងចំណុចនេះ សហព្រះរាជអាជ្ញានៅតែប្រកាន់ជំហរថា ច្បាប់កោសលុបជាសាធារណៈនៃដីកាដំណោះស្រាយ(សម្អាងហេតុ) មិនបានបំពេញនូវលក្ខខណ្ឌតម្រូវជាមូលដ្ឋាន ក្នុងការធានាចំពោះតម្លាភាពនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការឡើយ ដោយសារតែទំហំនៃការកោសលុបនៅក្នុងឯកសារនោះ[23]។

---

[20] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១។

[21] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កំណត់សម្គាល់ជើងទំព័រ ៣៧។

[22] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កំណត់សម្គាល់ជើងទំព័រ ៣៧។

[23] *សូមអាន,* **D309/2/1/2** បណ្ដឹងឧទ្ធរណ៍របស់ សពអ ប្រឆាំងនឹងការកោសលុបក្នុងដីកាដំណោះស្រាយ។

12. **<u>ការជូនដំណឹងដល់សាធារណជនជាប្រចាំ:</u>** អ៊ឹម ចែម តវ៉ាថា ការធ្វើចំណាត់ថ្នាក់ឡើងវិញនៃចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់គាត់ នឹងផ្តល់លទ្ធភាពឲ្យ "សាធារណជន [...] បានពិនិត្យមើលលើសេចក្តីសន្និដ្ឋានរបស់ភាគី និងដីកាដំណោះស្រាយ(សម្អាងហេតុ) របស់សហចៅក្រមស៊ើបអង្កេត ទៅតាមបរិបទរបស់វា [និង] ជួយលុបបំបាត់ការយល់ខុសពាក់ព័ន្ធនឹងផ្នែកសម្រេចសេចក្តីនៃរឿងក្តីនេះ"[24]។ ជាថ្មីម្តងទៀត អំណះអំណាងនេះសំអាងលើការសន្មតខុស ព្រោះការចេញសំណៅកោសលុបជាសាធារណៈនៃសេចក្តីសន្និដ្ឋាននានារបស់ភាគី ក្នុងខណៈដែលនៅរក្សាលទ្ធផលរកឃើញចុងក្រោយនៅក្នុងដីកាដំណោះស្រាយ(សម្អាងហេតុ)របស់ សចស នៅមានការលាក់បាំង នឹងជួយឲ្យមានការយល់ដឹងអំពីដំណោះស្រាយនៃរឿងក្តីនេះត្រឹមកម្រិតណាមួយនោះ។

13. អ៊ឹម ចែម ពីមុនបានអះអាងថា ការកោសលុបទាំងឡាយដែលបានប្រើប្រាស់នៅក្នុងដីកាដំណោះស្រាយ (សម្អាងហេតុ) គឺ "មិនមានភាពចាំបាច់សម្រាប់ឲ្យយល់ដឹងទាំងស្រុងនូវផ្នែកសេចក្តីសម្រេចនោះទេ ហើយមិនបានបម្រើដល់ផលប្រយោជន៍យុត្តិធម៌ដែរ ចំពោះការដាក់បង្ហាញព័ត៌មានទាំងនេះ"[25]។ ហើយឥឡូវនេះ បានលើកឡើងថា សាធារណជនគឺ "នៅតែមិនបានដឹងអំពីអំណះអំណាងរបស់ក្រុមការពារក្តី ដែលពន្យល់អំពីផ្នែកនៃសេចក្តីសម្រេចចុងក្រោយ"[26]។ យ៉ាងណាក៏ដោយ ដីកាដំណោះស្រាយ (សម្អាងហេតុ) ដែលកោសលុប មិនបានពន្យល់ឲ្យបានត្រឹមត្រូវនូវផ្នែកសម្រេចសេចក្តីនៃសំណុំរឿងនេះទេ ដោយសារតែការកោសលុបទូលាយ ត្រូវបានអនុវត្តដោយ សចស។ ការលើកឡើងរបស់ អ៊ឹម ចែម ដែលថា ការធ្វើឲ្យចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពរឲ្យទៅជាសាធារណៈ ខណៈដែលរក្សាទុកនូវដីកាដំណោះស្រាយ(សម្អាងហេតុ) ដែលកោសលុប នឹងបំភ្លឺដល់សាធារណជននូវផ្នែកសម្រេចសេចក្តីនៃករណីរឿងនេះ គឺយ៉ាងហោចណាស់ជាការបំភាន់ភ្នែក។

14. អ៊ឹម ចែម មិនអាចជ្រើសរើសតាមអំពើចិត្តនូវព័ត៌មានអ្វីដែលគាត់ចូលចិត្ត និងអ្វីដែលគាត់ពិចារណាថា នឹងគាំទ្រនូវគោលជំហររបស់គាត់ និងផ្សព្វផ្សាយទៅកាន់សាធារណជនបាននោះទេ។ វាជាការមិនខ្ជាប់ខ្ជួននោះទេដែលពោលអះអាងថា អំណះអំណាងរបស់ភាគីនានាត្រូវបានធ្វើឡើងជាសាធារណៈ ប៉ុន្តែមិនមែនចំពោះការពិចារណារបស់ សចស សម្រាប់ទទួលយក ឬក៏ច្រានចោល

---

[24] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ២១។

[25] **D309/2/1/3** ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ សពអ ស្តីពីការកោសលុបដីកាដំណោះស្រាយ, កថាខណ្ឌ៦០។

[26] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ២០។

នូវអំណះអំណាងដដែលនោះទេ។ អ៊ឹម ចែម ចង់ឲ្យសាធារណជនដឹងអំពីការអះអាងរបស់គាត់ ដែលថា ដីកាសន្និដ្ឋាននានារបស់សហព្រះរាជអាជ្ញា គឺខុស[27] ហើយអង្គហេតុសុទ្ធសាធនៃសំណុំរឿងនោះ ត្រូវបានបដិសេធ ដោយ សចស[28] - ប៉ុន្តែមិនបានគាំទ្រធ្វើឲ្យសនិទានភាព និងការពិចារណារកហេតុផលរបស់ សចស ឬមួយក៏អំណះអំណាងរបស់សហព្រះរាជអាជ្ញា លើបណ្ដឹងឧទ្ធរណ៍ អាចមានទៅបាននោះទេ។

15. ជាការហួសចិត្ត ការអះអាងរបស់ អ៊ឹម ចែម ដែលថា ការចាត់ថ្នាក់ឯកសារដែលបានជ្រើសរើសដែលបាស្នើសុំនេះ នឹងធ្វើឲ្យប្រាកដថា "ការផ្សព្វផ្សាយនូវព័ត៌មានសំខាន់ៗដែលមានភាពត្រឹមត្រូវ និងមានតុល្យភាព ដើម្បីផ្ដល់ការយល់ដឹងជាសាធារណៈឲ្យបានពេញលេញអំពីដំណើរការនីតិវិធី"[29]។

## IV. ការកោសលុបដែលបានលើកឡើងនេះ គឺទូលំទូលាយដោយមិនចាំបាច់

16. អ៊ឹម ចែម អះអាងថា ការកោសលុបដែលបានលើកឡើងរបស់គាត់នេះ "គឺប្រកបដោយតុល្យភាព សមរម្យ និងមានភាពចាំបាច់រវាង" ទំនុកចិត្តនៃកិច្ចស៊ើបសួរ និងផលប្រយោជន៍នៃតម្លាភាព នៅក្នុងកិច្ចដំណើរការនីតិវិធី[30]។ យ៉ាងណាក៏ដោយ ការកោសលុបជាច្រើន គឺបានបម្រើដោយខ្លួនឯង ដោយសារតែវាមិនបានដាក់បញ្ចូលនូវភស្តុតាង ដែលនៅលើភស្តុតាងនោះមានការអះអាងនានា ជាមូលដ្ឋាន ដូច្នេះហើយវាមិនបានផ្ដល់នូវរូបភាពពេញលេញ និងប្រកបទៅដោយតម្លាភាពនៃសំណុំរឿងនោះទេ។

17. ទីមួយ សំណើរបស់ អ៊ឹម ចែម ឲ្យកោសលុបភស្តុតាង *ទាំងអស់* របស់សាក្សី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីណាម្នាក់ គឺមិនចាំបាច់នោះទេ ក្នុងការធានាថាអត្តសញ្ញាណរបស់បុគ្គលបែបដូច្នោះត្រូវបានរក្សាទុកជាការសម្ងាត់ ហើយសុវត្ថិភាពរបស់ពួកគាត់ត្រូវបានធានា[31]។ ការកោសលុបឈ្មោះរបស់សាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណី និងការកំណត់អត្តសញ្ញាណ

[27] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ២០។

[28] **D309/2/1/3** ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ សពអ ស្ដីពីការកោសលុបដីកាដំណោះស្រាយ។

[29] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១៨។ *សូមអានផងដែរ*, កថាខណ្ឌ១។

[30] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១៥។

[31] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១៧។

លើព័ត៌មានរបស់បុគ្គលណាមួយ គឺវាគ្រប់គ្រាន់រួចទៅហើយសម្រាប់តម្រូវតាមការអនុវត្តរបស់តុលាការសម្រាប់ការចំណាត់ថ្នាក់ឡើងវិញ។ ការដកហូតនូវដានទាំងអស់ចេញពីភស្តុតាងជាមូលដ្ឋាន នឹងបន្សល់ទុកឱ្យសាធារណជននៅជាមួយនឹងការអះអាងរបស់ភាគីនានា ដោយដកហូតនូវបរិបទដែលនៅក្នុងនោះ ដីកាសន្និដ្ឋានបែបដូច្នេះត្រូវបានធ្វើឡើង និងជាមូលដ្ឋានសម្រាប់ភាពត្រឹមត្រូវរបស់ភស្តុតាងទាំងនោះ។

18. ទីពីរ ផ្ទុយពីសំណើរបស់ អ៊ឹម ចែម[32] - សហព្រះរាជអាជ្ញាសន្និដ្ឋានថា វាមិនមានមូលដ្ឋានត្រូវកោសលុបឈ្មោះរបស់មន្ត្រីផ្លូវការខ្មែរក្រហម នៅក្នុងដីកាសន្និដ្ឋាននានានៃសំណុំរឿង០០៤/០១ នោះឡើយ។ មន្ត្រីផ្លូវការនានារបស់ បកក ត្រូវបានដាក់ឈ្មោះយ៉ាងជាប់លាប់នៅក្នុងឯកសារសាធារណៈ ដែលបានចេញដោយអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល[33]។ សេចក្តីយោងរបស់ អ៊ឹម ចែម ចំពោះការកោសលុបឈ្មោះរបស់ តាប៉ាល់ នៅក្នុងដីកាដំណោះស្រាយ (សម្អាងហេតុ) គឺគ្រាន់តែបានបកស្រាយបង្ហាញពីវិធីសាស្ត្រទូលំទូលាយដោយមិនចាំបាច់ ដែលបានប្រើប្រាស់ដោយ សចស តែប៉ុណ្ណោះ[34]។ ឈ្មោះរបស់ តាប៉ាល់ មានលេចឡើងនៅកណ្តាលវាក្យខណ្ឌចំនួន ១៤៤ តៗគ្នាជាប់មិនដាច់ ដែលថាត្រូវបានកោសលុបនៅក្នុងភាពទាំងស្រុងរបស់វា[35]។ សនិទានភាពរបស់ សចស សម្រាប់ការកោសលុបឈ្មោះរបស់ តាប៉ាល់ ក៏ដូចជាសនិទានភាពសម្រាប់កោសលុបភាគច្រើននៃខ្លឹមសារនៃដីកាដំណោះស្រាយ(សម្អាងហេតុ) ដែរ គឺពុំមានយុត្តិកម្មណាមួយ យកជាការបាននោះទេ[36]។

19. ទីបី អ៊ឹម ចែម កោសលុបដោយមិនត្រឹមត្រូវលើសេចក្តីយោងទាំងអស់ទៅនឹងសេចក្តីថ្លែងផ្ទាល់របស់គាត់[37]។ សេចក្តីថ្លែងរបស់ អ៊ឹម ចែម ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្តជូនទៅ DC-Cam

---

[32] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១៧។

[33] *សូមអាន,* ឧទា. សំណុំរឿង០០១-**E188** សាលក្រម, ២៦ កក្កដា ២០១០។ សំណុំរឿង០០១-**F28** សាលដីកាឧទ្ធរណ៍, ៣ កុម្ភៈ ២០១២។ សំណុំរឿង០០២-**E313** សាលក្រម, ៧ សីហា ២០១៤។ សំណុំរឿង០០២-**F36** សាលដីកាឧទ្ធរណ៍, ២៣ វិច្ឆិកា ២០១៦។

[34] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១៧។

[35] **D308/3** ដីកាដំណោះស្រាយ (សម្អាងហេតុ), កថាខណ្ឌ ១៨០-៣២៤។

[36] *សូមអាន,* **D309/2/1/2** បណ្តឹងឧទ្ធរណ៍របស់ សពអ ស្តីពី ការកោសលុបដីកាដំណោះស្រាយ។

[37] *សូមអាន,* **D304/6/1.2** [កោសលុប] ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងខ្លួន តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង, កំណត់សម្គាល់ជើងទំព័រលេខ 205-206, 219, 222-223, 226, 273,

និងជូនទៅអង្គការនានាដទៃទៀត ហើយក៏មិនបង្កើតជាការរំពឹងទុកថាត្រូវតែជាការសម្ងាត់នោះដែរ។ អ៊ឹម ចែម មិននៅក្នុងការជាប់ឃុំឃាំង ឬឃាត់ខ្លួននៅពេលនោះទេ ហើយបុគ្គលនានាដែលគាត់បាននិយាយទៅកាន់នោះ ក៏មិនមែនជាអ្នកប្រតិបត្តិច្បាប់ដែរ។ អ៊ឹម ចែម ស្វែងរកធ្វើ ការសម្អាតឱ្យជ្រះស្រឡះឡើងវិញលើការដាក់ញត្តិរបស់គាត់ ដោយការដកចេញនូវសេចក្តីថ្លែងផ្ទាល់នានារបស់គាត់ ព្រោះវានាំឱ្យមានភាពផ្ទុយគ្នាពីការប៉ុនប៉ងបច្ចុប្បន្នរបស់គាត់ក្នុងការបង្ហាញដោយខុសឆ្គងនូវអំពើ និងសកម្មភាពរបស់គាត់ នៅក្នុងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អ៊ឹម ចែម ពីមុនបានជជែកសុំ *បង្កើន* ការកោសលុបទូលាយ ដែលបានទទួលយកដោយ សចស នៅក្នុងដីកាដំណោះស្រាយ (សម្អាងហេតុ) ដោយរាប់បញ្ចូលទាំងការកោសលុបសេចក្តីយោងនានាទៅនឹងសេចក្តីថ្លែងរបស់ អ៊ឹម ចែម ផង[38]។ ដូច្នេះ គោលជំហររបស់ អ៊ឹម ចែម គឺធ្វើព័ត៌មានឱ្យមានបានទៅដល់សាធារណជន តែកាលណាវាមានជាប់ទាក់ទងជួយគាំទ្រទៅនឹងអំណះអំណាងរបស់គាត់តែប៉ុណ្ណោះ។ ប៉ុន្តែ កាលណាពាក្យពេចន៍ផ្ទាល់របស់គាត់ មិនត្រូវបានយល់ស្របច្រើនទេនោះ - គឺហ្នឹងហើយដែលអំណះអំណាងទាំងនោះនៅតែត្រូវបានបិទបាំង។

20. សហព្រះរាជអាជ្ញាយល់ស្របថា ឈ្មោះរបស់ អ៊ឹម ចែម មិនត្រូវបានកោសលុបចេញពីដីកាសន្និដ្ឋាននានាទេ[39]។ ដែលថាគាត់ជាប្រធានបទនៃសំណុំរឿង០០៤/០១ គឺជាព័ត៌មានដែលគេអាចរកបានជាសាធារណៈ។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាយល់ស្របទៅនឹងការទុកសេចក្តីយោងទាំងអស់ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់គាត់ និងឯកសារនានា បែបដូចជា សេចក្តីជូនដំណឹងអំពីគោលបំណងរបស់ សចស ចំពោះការលើកលែងការចោទប្រកាន់ដែលមិនបានកោសលុប[40] ក្នុងករណីដែលអំណះអំណាងនោះ និងដីកាសន្និដ្ឋានជាមូលដ្ឋាននានា ត្រូវបានចាត់ថ្នាក់ឡើងវិញក្នុងគោលបំណងផ្តល់នូវរូបភាពតម្លាភាពមួយនៃការវិវត្តន៍នៃកិច្ចដំណើរការនិតិវិធី។ ចំពោះការចាត់ថ្នាក់ឯកសារនានាដោយជ្រើសរើសបែបដូច្នេះ នឹងដកហូតនូវចំណេះដឹងរបស់របស់សាធារណជនចេញពីអង្គហេតុជាក់លាក់ និងការអះអាងតាមផ្លូវច្បាប់ដែល អ៊ឹម ចែម កំពុងលើក

---

323-324, 332, 385, 389, 406, 411, 455, 456-465, 468, 471, 476, 483, 486, 490-491, 507-508, 513, 715, 739, 755, 763។

[38] **D309/2/1/3** ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ សពអ ស្តីពីការកោសលុបដីកាដំណោះស្រាយ, កថាខណ្ឌ៧៥។

[39] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១៧។

[40] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១៧។

ឡើងនៅក្នុងចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពរ និងមូលដ្ឋានភស្តុតាងដែលជាមូលដ្ឋានរបស់វា។ ការណ៍នេះ គ្រាន់តែបានផ្តល់នូវការរៀបរាប់តែមួយខាងប៉ុណ្ណោះ។

## V. **សេចក្តីសន្និដ្ឋាន**

21. អ៊ឹម ចែម បានកត់សម្គាល់បានត្រឹមត្រូវថា មានការព្រមព្រៀងគ្នាមួយរវាងភាគីនានាថា ការចាត់ថ្នាក់ឡើងវិញនៃចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពរ "នឹងមិនប៉ះពាល់ដល់អត្ថប្រយោជន៍ណាមួយ ដែលកន្លងទៅ ត្រូវបានការពារដោយភាពសម្ងាត់នៃកិច្ចស៊ើបសួរតាមផ្លូវតុលាការនោះទេ"[41]។ ដោយមានសនិទានភាពដូចគ្នាទៅនឹងអ្វីដែល អ៊ឹម ចែម បានអនុវត្តនៅក្នុងសំណើរបស់គាត់ ត្រូវតែមានការព្រមព្រៀងគ្នារវាងភាគីនានានៅពេលនេះផងដែរ ដែលថាញត្តិរបស់ភាគីនានា ក៏ដូចជាសេចក្តីសម្រេចរបស់ សចស និងអង្គបុរេជំនុំជម្រះ ត្រូវតែបានចាត់ថ្នាក់ឡើងវិញជាសាធារណៈ ដោយមានការកោសលុបទាំងឡាយណាដែលចាំបាច់តែប៉ុណ្ណោះ ដើម្បីការពារអត្តសញ្ញាណ និងសុវត្ថិភាពរបស់សាក្សី និងជនរងគ្រោះ។

22. អ៊ឹម ចែម ស្វែងរកឱ្យបានអំណះអំណាងរបស់គាត់នៅក្នុងសង្ខេបសាធារណៈ ប៉ុន្តែពុំមានភស្តុតាងណាមួយដែលនៅលើនោះ គាត់យកធ្វើជាមូលដ្ឋាននោះទេ ឬសនិទានភាពរបស់ សចស និងការពិចារណារកហេតុផលនៅក្នុងការធ្វើយុត្តិកម្មទៅលើអំណះអំណាង។ យ៉ាងណាក៏ដោយ អ៊ឹម ចែម មិនអាចអះអាងដោយគួរឱ្យជឿជាក់បានថា ការចាត់ថ្នាក់ឡើងវិញនូវចម្លើយតបរបស់គាត់ទៅនឹងដីកាសន្និដ្ឋានស្ថាពរ និងការមិនចាត់ថ្នាក់ឡើងវិញលើឯកសារនានា បែបដូចជា ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ប្រតិចារឹកនៃសវនាការបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ការដាក់ឯកសារពាក់ព័ន្ធ ក៏ដូចជា ការដាក់បង្ហាញសំណៅទាំងស្រុងនៃដីកាដំណោះស្រាយ (សម្អាងហេតុ) នឹងជួយដល់ផលប្រយោជន៍នៃយុត្តិធម៌ ឬតម្លាភាពនៃកិច្ចដំណើរការនីតិវិធីព្រមទាំង កេរ្តិ៍ដំណែលរបស់ អ.វ.ត.ក ផងដែរ។

## V. **ដំណោះស្រាយដែលស្នើសុំ**

23. ចំពោះមូលហេតុនានាខាងលើនេះ សហព្រះរាជអាជ្ញា គាំទ្រសំណើរបស់ អ៊ឹម ចែម ដោយមានការកែប្រែទៅលើការកោសលុបដែលបានស្នើឡើង។ សហព្រះរាជអាជ្ញា ស្នើសុំបន្ថែមទៀតថា

---

[41] **D304/6/1** សំណើរបស់ អ៊ឹម ចែម, កថាខណ្ឌ១៦។

ប្រតិចារឹកនៃសវនាការបណ្ដឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ទាក់ទងទៅនឹងការដាក់ឯកសារនានា និងដីកាដំណោះស្រាយ (សម្អាងហេតុ) ទាំងស្រុង គួរត្រូវបានបញ្ចេញជាសាធារណៈ ដោយស្ថិតនៅក្រោមការកោសលុបចាំបាច់ណាដែលត្រូវការពារដល់សាក្សី និងជនរងគ្រោះប៉ុណ្ណោះ៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |